សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ!
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!
- បងប្អូនជនរួមជាតិជាទីស្រឡាញ់រាប់អាន!

ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមចូលរួមជាមួយពិភពលោកទាំងមូលដើម្បីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ១រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០នេះ ក្រោមប្រធានបទ "**សាមគ្គីភាពជាសកល និងការទទួលខុសត្រូវរួមគ្នា**"។ ទិវានេះប្រារព្ធឡើងក្នុងគោលបំណងរួមគ្នាជាសកលដើម្បីបង្ហាញនូវការគាំទ្រដល់អ្នកផ្ទុកនិងអ្នករងផលប៉ះពាល់ពីមេរោគអេដស៍ ហើយនិងរំឭកដល់អ្នកដែលបានបាត់បង់ជីវិតដោយសារជំងឺអេដស៍។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងការគាំទ្រពេញទំហឹងចំពោះគ្រប់សកម្មភាពទាំងអស់ដែលបាននិងកំពុងអនុវត្តក្នុងការជំរុញការយល់ដឹងជាសាធារណៈឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស ដើម្បីផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តប្រឈមនឹងការឆ្លង ការចម្លងមេរោគអេដស៍ និងដើម្បីសុខភាពល្អរបស់យើងទាំងអស់គ្នា។ ពិតណាស់ថា ជំងឺអេដស៍មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាពនិងអាយុជីវិតតែប៉ុណ្ណោះទេ ថែមទាំងបង្កនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចយ៉ាងខ្លាំងទៀតផង។ តាមទស្សនទាននេះ យើងទាំងអស់គ្នាចាំបាច់ត្រូវបន្តយកចិត្តទុកដាក់ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ដោយមិនត្រូវធ្វេសប្រហែសឡើយ។ យើងប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០ ក្រោមប្រធានបទ "**សាមគ្គីភាពជាសកល និងការទទួលខុសត្រូវរួមគ្នា**" នេះ ដើម្បីបង្ហាញការចូលរួមទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ដែលអង្គការសហប្រជាជាតិបានកំណត់ថាឱ្យអស់អេដស៍នៅឆ្នាំ២០៣០។

តាមរបាយការណ៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្ហាញថា អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យ ដែលមានអាយុចាប់ពី១៥ ដល់៤៩ឆ្នាំ បានថយចុះពី០,៨% នៅឆ្នាំ២០១០ មក

នៅត្រឹម០,៥% នៅឆ្នាំ២០១៩។ ក្នុងនោះ ចំនួនអ្នកស្លាប់គ្រប់វ័យដោយសារជំងឺអេដស៍បានថយចុះពីចំនួនប្រមាណ២ ៣០០នាក់ នៅឆ្នាំ២០១០ មកនៅត្រឹមចំនួនប្រមាណ១ ៣០០នាក់ក្នុងឆ្នាំ២០១៩។ បច្ចុប្បន្ននេះ ចំនួនអ្នកផ្ទុកមេរោគអេដស៍គ្រប់វ័យមានប្រមាណ៧៣ ០០០នាក់ ក្នុងនោះ ៨៤% បានធ្វើតេស្តឈាមដឹងពិតប្រាកដថា បានផ្ទុកមេរោគអេដស៍១០០% បានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៦% ទទួលបានប្រសិទ្ធភាពនៃការព្យាបាលនាំឱ្យមានសុខភាពល្អ។ ចំនួនអ្នកឆ្លងថ្មីគ្រប់វ័យ បានថយចុះពីចំនួនប្រមាណ១ ៩០០នាក់ នៅឆ្នាំ២០១០ មកនៅត្រឹមប្រមាណ៧៨០នាក់ នៅឆ្នាំ២០១៩។

សមិទ្ធផលទាំងនេះ កំពុងតែបង្ហាញឱ្យឃើញនូវសញ្ញាវិជ្ជមានលើប្រសិទ្ធភាពនិងគុណភាពខ្ពស់នៃកិច្ចអន្តរាគមន៍របស់យើង ក្នុងការទប់ស្កាត់ការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចបានគោលដៅ **៩៥ ៩៥ ៩៥** ឬគោលដៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥ គឺ៥ឆ្នាំមុនកាលកំណត់របស់អង្គការសហប្រជាជាតិ។

ក៏ប៉ុន្តែ យើងមិនត្រូវភ្លេចខ្លួន ស្កប់ស្កល់ជាមួយជោគជ័យដែលយើងទទួលបាននោះឡើយ ព្រោះថាចាប់តាំងពីមានការរាតត្បាតមេរោគអេដស៍ក្នុងទសវត្សរ៍ឆ្នាំ១៩៨០មក រហូតដល់ពេលនេះ ពិភពលោកមិនទាន់រកឃើញវ៉ាក់សាំង ឬឱសថព្យាបាលជំងឺអេដស៍ឱ្យជាសះស្បើយជាស្ថាពរនៅឡើយទេ។ ម៉្យាងទៀត នៅកម្ពុជា យើងមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ១២ ០០០នាក់ នៅមិនទាន់បានត្រលប់មកធ្វើតេស្តឈាមដើម្បីបញ្ជាក់ពិតប្រាកដអំពីស្ថានភាពមេរោគអេដស៍នៅក្នុងខ្លួននោះទេ។ អ្នកជំងឺអេដស៍មួយចំនួនទៀតបាន និងកំពុងលះបង់ការព្យាបាលឡើងវិញ។ ជាមួយគ្នានោះ ប្រជាជនគន្លឹះដូចជា ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ស្ត្រីបម្រើសេវាកម្សាន្តសប្បាយមានចំនួនកើនឡើង និងមានអត្រាឆ្លងមេរោគអេដស៍ខ្ពស់ ដែលអាចនាំឱ្យមានការចម្លងមេរោគអេដស៍ទៅប្រជាពលរដ្ឋទូទៅទៀតផង។

នៅចំពោះមុខហានិភ័យនៃការរីករាលដាលឡើងវិញនៃជំងឺអេដស៍ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវជាថ្មីម្តងទៀតដល់ជនរួមជាតិយើង ទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ ឱ្យខិតខំទប់ស្កាត់មេរោគអេដស៍និងជំងឺអេដស៍ ដោយចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងចរន្តជាតិតែមួយ ឆ្ពោះទៅបញ្ចប់អេដស៍នៅកម្ពុជានៅឆ្នាំ២០២៥ខាងមុខដោយជោគជ័យ។ ការចូលរួមទាំងនោះរួមមាន ការធ្វើតេស្តឈាមរកមេរោគអេដស៍ ការប្រើប្រាស់ស្រោមអនាម័យឱ្យបានទូលំទូលាយ ការមិនរើសអើងអ្នកផ្ទុកមេរោគអេដស៍ និងការជួយឧបត្ថម្ភគាំទ្រអ្នកផ្ទុកមេរោគអេដស៍ដែលជាជនក្រីក្រជាដើម។

រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍ជាអាទិភាពខ្ពស់ ព្រោះមេរោគអេដស៍ជាការគំរាមកំហែងដល់សុខភាពសាធារណៈ ដែលជាគ្រោះថ្នាក់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋ និងដែលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលដែលមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាសេនាធិការ នឹងបន្តខិតខំចាត់វិធានការគ្រប់យ៉ាង ដើម្បីឈានទៅសម្រេចគោលដៅដូចតទៅ ៖ អ្នកឆ្លងមេរោគអេដស៍ថ្មីមិនលើសពីមួយនាក់ក្នុងមួយថ្ងៃ និងអ្នកស្លាប់ដោយសារជំងឺអេដស៍មិនលើសពីបីនាក់ក្នុងមួយថ្ងៃ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានជំនឿយ៉ាងមុតមាំថា កម្ពុជាយើងអាចសម្រេចគោលដៅនេះបាន ដោយសារកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍របស់យើងឈរលើមូលដ្ឋាន៣ដូចខាងក្រោម ៖

១- ភាពម្ចាស់ការនិងភាពជាអ្នកនាំមុខ ៖ រាជរដ្ឋាភិបាលបាននិងកំពុងដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ដោយផ្ទាល់និងយ៉ាងសកម្ម។ កន្លងមក ក្រសួងមហាផ្ទៃបានបញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ក្នុងគោលនយោបាយភូមិឃុំមានសុវត្ថិភាព រីឯក្រសួងផែនការក៏បានផ្តល់អត្តសញ្ញាណកម្មអ្នកក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបាននូវការគាំពារសង្គមដូចប្រជាជនក្រីក្រទូទៅដែរ។ បច្ចុប្បន្ន យើងកំពុងបញ្ជ្រាបកម្មវិធីអេដស៍ទៅក្នុងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ នៅក្នុងក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍កំពុងធ្វើការផ្ទាល់ជាមួយរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីឱ្យអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចូលរួមបង្ការការពារកុំឱ្យមានការរីករាលដាលនៃមេរោគអេដស៍ ជួយរកអ្នកផ្ទុកមេរោគអេដស៍ឱ្យមកទទួលសេវាព្យាបាល ជួយបង្កលក្ខណៈកុំឱ្យមានការរើសអើងអ្នកផ្ទុកមេរោគអេដស៍ ជួយស្វែងរក និងជួយផ្តល់ការឧបត្ថម្ភតាមរយៈប្រព័ន្ធគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍នៅក្នុងមូលដ្ឋាននីមួយៗ។

២- ភាពជាដៃគូ ៖ រាជរដ្ឋាភិបាលបាននិងកំពុងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធនិងដោយប្រសិទ្ធភាពជាមួយដៃគូទាំងអស់រួមមាន ប្រទេសផ្តល់ជំនួយ អង្គការអន្តរជាតិ មានជាអាទិ៍ អង្គការសុខភាពពិភពលោក (WHO) កម្មវិធីរួមអង្គការសហប្រជាជាតិទទួលបន្ទុកការងារអេដស៍ (UNAIDS) មូលនិធិសកល (Global Fund) និងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិដែលបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍នៅកម្ពុជា។

តាមរយៈកិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានទទួលស្គាល់សារៈសំខាន់របស់អង្គការសង្គមស៊ីវិល ក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។ បើគ្មានកិច្ចសហការដ៏ជិតស្និទ្ធក្នុងភាពជាដៃគូនេះទេ យើងក៏មិនអាចសម្រេចជោគជ័យបានឡើយ។

៣- ការវិនិយោគ ៖ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ពិភពលោកបានចំណាយទុនរាប់ពាន់លានដុល្លារ។ ដោយឡែក នៅកម្ពុជាយើង មូលនិធិសកលនិងដៃគូអភិវឌ្ឍដទៃទៀតបានចំណាយធនធានជាច្រើនរយលានដុល្លាររួចមកហើយ។ ចំណែករាជរដ្ឋាភិបាលក៏បានចូលរួមចំណែកបង្កើនថវិកាក្នុងកម្មវិធីអេដស៍កាន់តែច្រើនឡើងៗជាទៀងទាត់ ពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឱ្យថវិកាបដិភាគរបស់យើងឡើងដល់ជាង១ភាគ៣ នៃការចំណាយទាំងអស់ក្នុងការប្រយុទ្ធនឹងជំងឺនេះ។ ជាក់ស្តែង ពីឆ្នាំ២០២១ ដល់២០២៣ រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាបដិភាគចំនួន១៩,៦៥លានដុល្លារ ដែលក្នុងនោះមានថវិកាចំនួន ១១លានដុល្លារសម្រាប់ទិញឱសថព្យាបាលអ្នកជំងឺអេដស៍។

ដើម្បីឈានទៅរកចីរភាពនៃកម្មវិធីនាពេលអនាគត ក្នុងពេលដែលជំនួយអន្តរជាតិកាន់តែចុះថយនោះ រាជរដ្ឋាភិបាលនឹងខិតខំបង្កើនថវិកាជាតិជួយទិញឱសថព្យាបាលអ្នកជំងឺអេដស៍តទៅទៀត ជាមួយនឹងការពង្រីកថវិកាសេវាសង្គមនៅថ្នាក់ក្រោមជាតិ ដើម្បីឱ្យមន្ត្រីមូលដ្ឋានក្នុងឃុំ សង្កាត់អាចប្រើប្រាស់ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍បានទៅតាមលទ្ធភាពនៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ។

ការខិតខំរបស់រាជរដ្ឋាភិបាលបានឆ្លុះបញ្ចាំងអំពីឆន្ទៈដ៏មោះមុតរបស់យើងទាំងអស់គ្នា ឆ្ពោះទៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមឧទ្ទិសខ្លឹមសារនិងអត្ថន័យនៃទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០ ក្រោមប្រធានបទ “**សាមគ្គីភាពជាសកល និងការទទួលខុសត្រូវរួមគ្នា**” ឱ្យក្លាយជាចរន្តជាតិដ៏ធំធេងមួយ ដើម្បីឈានទៅសម្រេចគោលដៅ៣គឺ ៖ **គ្មានអ្នកឆ្លងថ្មី គ្មានអ្នកស្លាប់ដោយសារជំងឺអេដស៍ និងគ្មានការរើសអើងអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍។**

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវឱ្យគ្រប់ក្រសួង ស្ថាប័ន មន្ទីរ រាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ធ្វើការរួមគ្នាជាពហុវិស័យ សហការយ៉ាងជិតស្និទ្ធជាមួយកាកបាទក្រហមកម្ពុជា អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន អ្នកផ្ទុកមេរោគអេដស៍ ក្រុមប្រជាជនគន្លឹះ និងសហគមន៍ ដើម្បីលុបបំបាត់ការចម្លងមេរោគអេដស៍ និងយកជ័យជម្នះលើមេរោគអេដស៍ឱ្យបានតាមកាលកំណត់។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរនិងប្រគេនពរ សម្តេចព្រះមហាសង្ឃរាជ ព្រះថេរានុត្ថេរៈ និងជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗយុវជន យុវតី សិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ពុធ ១០កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២០

**ហ៊ុន សែន**